# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភាប្រចាំខែសីហា ឆ្នាំ២០២២

នៅក្នុងខែសីហា ឆ្នាំ២០២២នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចដូចតទៅ៖

## ១-សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា

១.១-សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា

-បានបំពេញភារកិច្ចជាប្រមុខរដ្ឋស្តីទី ចាប់ពីថ្ងៃទី២១ ខែសីហា ឆ្នាំ២០២២។

១.១.១-សកម្មភាពចូលរួមកិច្ចប្រជុំ

-បានអញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ចំនួន២លើក និងបើកសម័យប្រជុំលើកទី៩ ព្រឹទ្ធសភា នីតិកាលទី៤ ចំនួន១លើក។

១.១.២-បដិសណ្ឋារកិច្ចឡៃជាតិ-អន្តរជាតិ

-បានអនុញ្ញាតឱ្យឯកឧត្តម **ឡេ ហាយជុង** ប្រធានគណៈទាក់ទងបរទេសនៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តវៀតណាម ចូលជួបសម្តែងការគួរសម និងសវនាការ នៅវិមានព្រឹទ្ធសភា។

-បានអនុញ្ញាតឱ្យលោកជំទាវ **ង្វៀន ធីថាញ់** សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភានៃសាធារណរដ្ឋសង្គមនិយមវៀតណាម និងជាប្រធានសមាគមមិត្តភាពវៀតណាម-កម្ពុជា និងគណៈប្រតិភូ ចូលជួបសម្តែងការគួរសម និងសវនាការ នៅវិមានព្រឹទ្ធសភា។

-បានអនុញ្ញាតឱ្យលោក **Kim Jung Nam** ប្រធានមូលនិធិចែករំលែកសង្គ្រោះជីវិតសកល **(Global Life Sharing)** នៃសាធារណរដ្ឋកូរ៉េ និងគណៈប្រតិភូ ចូលជួបសម្តែងការគួរសម និងសវនាការ នៅវិមានព្រឹទ្ធសភា។

-បានអនុញ្ញាតឱ្យឯកឧត្តម **Vahram Kazhoyn** ឯកអគ្គរដ្ឋទូតតែងតាំងថ្មី នៃសាធារណរដ្ឋអាមេនី ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម និងសវនាការ នៅ



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

វិមានព្រឹទ្ធសភា។

**១.១.៣-សកម្មភាពចុះមូលដ្ឋាន**

-បានអញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខមន្ត្រី អាជ្ញាធរ និងកងកម្លាំងនគរបាលប៉ុស្តិ៍រដ្ឋបាល ក្នុងសង្កាត់បឹងព្រលិត ខណ្ឌ៧មករា រាជធានីភ្នំពេញ។

**១.១.៤-សកម្មភាពចូលរួមពិធីផ្សេងៗ**

-បានអញ្ជើញចូលរួមដង្ហែព្រះរាជដំណើរ**ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ស្តេចយាងពិនិត្យ និងព្យាបាលព្រះរាជសុខភាព នៅទីក្រុងប៉េកាំង នៃសាធារណរដ្ឋប្រជាមានិតចិន។

-បានអញ្ជើញគោរពវិញ្ញាណក្ខន្ធសពមហាវិរិយោភិវ័ឌ្ឍសិរី អគ្គមហាឧបាសកពុទ្ធសាសនុបត្ថម្ភក៍ **ខេវ៉ូ ស៊ុនស្រេង** ត្រូវជាឪពុកបង្កើតឯកឧត្តម **ស៊ុន ចាន់ថុល** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន នៅគេហដ្ឋានលេខ១៧ ផ្លូវលេខ៦០៤ សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

-បានអញ្ជើញចូលរួមក្នុងពិធីបុណ្យខួបគម្រប់១០០ថ្ងៃ ឧទ្ទិសកុសលជូនចំពោះដួងវិញ្ញាណក្ខន្ធសម្តេចឧត្តមទេពញាណ **ហ៊ុន ណេង** អតីតសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា និងជាអ្នកតំណាងរាស្ត្រ មណ្ឌលកំពង់ចាម នៅភូមិគ្រឹះក្នុងក្រុងកំពង់ចាម។

-បានអញ្ជើញដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធសព និងចូលរួមពិធីបុណ្យគម្រប់ខួប៧ថ្ងៃ និងរាប់បាត្រព្រះសង្ឃចំនួន៩២អង្គ ឧទ្ទិសកុសលជូនដល់ដួងវិញ្ញាណក្ខន្ធមហាឧបាសិកាកុសលចិត្តាមហាឧបាសិកាពុទ្ធសាសនុបត្ថម្ភក៍ **ពេន យុត** ម្តាយក្មេករបស់ឯកឧត្តម **ខៀវ កាញារីទ្ធ** រដ្ឋមន្ត្រីក្រសួងព័ត៌មាន នៅភូមិគ្រឹះលេខ៣៨ ផ្លូវលេខ២៨៥ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

-បានអញ្ជើញគោរពព្រះវិញ្ញាណក្ខន្ធព្រះអង្គីសម្តេច **ព្រះបរមរាមា នរោត្តម យុវនាថ** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅវត្តបទុមវតី សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

**១.១.៥-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ**

-បានចុះហត្ថលេខាលើព្រះរាជក្រឹត្យចំនួន៣៩ច្បាប់

-បានចុះហត្ថលេខាលើសំណើសុំព្រះរាជទានសិទ្ធិចំនួន២៣ច្បាប់

-បានទទួលព្រះរាជសារព្រះរាជទានសិទ្ធិចំនួន២៣ច្បាប់

-បានទទួលសំណើពីរាជរដ្ឋាភិបាលចំនួន២២ច្បាប់

-សំណើសម្តេចប្រមុខរដ្ឋស្តីទីចំនួន១ច្បាប់

-បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១៩ច្បាប់ និងជ្រាបជាព័ត៌មានចំនួន២០ច្បាប់។

**១.២ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ុម កា អនុប្រធានទី១ ព្រឹទ្ធសភា**

-បានទទួលភារកិច្ចជាប្រធានស្តីទីព្រឹទ្ធសភាចាប់ពីថ្ងៃទី២១ ខែសីហា ឆ្នាំ២០២២។

**១.២.១-សកម្មភាពចូលរួមកិច្ចប្រជុំ**

-បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ចំនួន២លើក និងបើកសម័យប្រជុំលើកទី៩ ព្រឹទ្ធសភា នីតិកាលទី៤ ចំនួន១លើក។

**១.២.២-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ**

-បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១៣ច្បាប់ និងជ្រាបជាព័ត៌មានចំនួន៥៥ច្បាប់។

**១.៣ ឯកឧត្តមកិត្តិសង្គហបណ្ឌិត ខេព ងន អនុប្រធានទី២ ព្រឹទ្ធសភា**

**១.៣.១-សកម្មភាពចូលរួមកិច្ចប្រជុំ**

-បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ចំនួន២លើក និងបើកសម័យប្រជុំលើកទី៩ ព្រឹទ្ធសភា នីតិកាលទី៤ ចំនួន១លើក។

**១.៣.២-សកម្មភាពចុះមូលដ្ឋាន**

-បានអនុញ្ញាតឱ្យក្រុមការងារដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្ត ទៅពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋនៅក្នុងឃុំមៀន ស្រុកអូរាំងឪ ខេត្តត្បូងឃ្មុំ។

**១.៣.៣-សកម្មភាពចូលរួមពិធីផ្សេងៗ**

-បានអញ្ជើញជាអធិបតីក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា (MOU) រវាងគណៈកម្មការទី១០ ព្រឹទ្ធសភា ជាមួយមូលនិធិចែករំលែកសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋកូរ៉េ ដើម្បីផ្តល់ជំនួយមនុស្សធម៌ដល់ព្រឹទ្ធសភា នៅវិមានព្រឹទ្ធសភា។

-បានអញ្ជើញចូលរួមក្នុងពិធីបុណ្យគម្រប់ខួប១០០ថ្ងៃ ដើម្បីឧទ្ទិសកុសលជូនចំពោះ

ដួងវិញ្ញាណក្ខន្ធសម្តេចឧត្តមទេពញាណ ហ៊ុន ណេង អតីតសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា និងជាអ្នកតំណាងរាស្ត្រមណ្ឌលកំពង់ចាម នៅភូមិគ្រឹះក្នុងក្រុងកំពង់ចាម។

-បានអញ្ជើញចូលរួមក្នុងពិធីបុណ្យគម្រប់ខួប៧ថ្ងៃ មហាឧបាសិកាកុសលចិត្តា មហាឧបាសិកាពុទ្ធសាសនុបត្ថម្ភក៏ **ពេន យុត** ម្តាយក្មេករបស់ ឯកឧត្តម **ខៀវ កាញារីទ្ធ** រដ្ឋមន្ត្រីក្រសួងព័ត៌មាន នៅភូមិគ្រឹះលេខ៣៨ ផ្លូវលេខ២៨៥ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

**១.៣.៨-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ**

-បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៣៦ច្បាប់ និងជ្រាបជាព័ត៌មានចំនួន១២ច្បាប់។

## ២.សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

ព្រឹទ្ធសភាបានបើកកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន២លើក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា ដើម្បីពិនិត្យ និងសម្រេចលើរបាយការណ៍ ស្តីពីសកម្មភាព និងលទ្ធផលការងាររបស់ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំលើកទី៨ និងលើកទី៩ នីតិកាលទី៤ និងពិនិត្យសំណើរបស់រដ្ឋសភា និងគណៈកម្មការជំនាញព្រឹទ្ធសភា ពិនិត្យ និងសម្រេចលើសេចក្តីព្រាងច្បាប់ចំនួន៤ច្បាប់។

## ៣.សម័យប្រជុំពេញអង្គព្រឹទ្ធសភា

ព្រឹទ្ធសភាបានបើកសម័យប្រជុំលើកទី៩ នីតិកាលទី៤ ចំនួន១លើក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា ដើម្បីស្តាប់របាយការណ៍របស់គណៈកម្មាធិការអចិន្ត្រៃយ៍ ស្តីពីសកម្មភាព និងលទ្ធផលការងាររបស់ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំលើកទី៨ និងលើកទី៩ ព្រឹទ្ធសភា នីតិកាលទី៤ ព្រមទាំងពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ចំនួន៤ ដូចខាងក្រោម៖

**១**-សេចក្តីព្រាងច្បាប់ធម្មនុញ្ញស្តីពី វិសោធនកម្មមាត្រា១៩ ថ្មី(មួយ) មាត្រា៨៩ មាត្រា៩៨ ថ្មី មាត្រា១០២ ថ្មី មាត្រា១១៩ ថ្មី(មួយ) និងមាត្រា១២៥ ថ្មី នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា៣ ថ្មី និងមាត្រា៤ ថ្មី នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ។

**២**-សេចក្តីព្រាងច្បាប់ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ។

**៣**-សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើ៖

១-កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃតំបន់សេដ្ឋកិច្ចពិសេសម៉ាកាវនៃសាធារណរដ្ឋប្រជាមានិតចិន ស្តីពីការលុបបំបាត់ការយកពន្ធត្រួតគ្នាពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការការគេចវេះពន្ធ និងការចៀសវាងពន្ធ។

២-កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋតួកគី ស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការកិបកេងបន្លំពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល។

**៤**-សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញា ស្តីពីជំនួយក្នុងករណីមានគ្រោះមហន្តរាយនុយក្លេអ៊ែរឬគ្រោះអាសន្នវិទ្យុសកម្ម។

**៥**-ស្តាប់របាយការណ៍ ស្តីពីសកម្មភាព និងលទ្ធផលការងាររបស់ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំលើកទី៨ និងលើកទី៩ នីតិកាលទី៤។

## ៤.គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា

សមាជិកព្រឹទ្ធសភា បានបំពេញការងារតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម៖

### ៤.១ មុខងារនីតិកម្ម

-បានអញ្ជើញចូលរួមប្រជុំជាមួយតំណាងរាជរដ្ឋាភិបាល ដឹកនាំដោយឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តម **ស៊ុយ សែម** រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល និងឯកឧត្តម **កើត រិទ្ធ** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដើម្បីពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ចំនួន៤ច្បាប់។

-បានអញ្ជើញប្រជុំតាមប្រព័ន្ធវីដេអូជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដឹកនាំដោយឯកឧត្តម **វង្សី វិស្សុត** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការប្រចាំការ ដើម្បីពិនិត្យពិភាក្សាលើគម្រោងថវិកាឆ្នាំ២០២៣ របស់ព្រឹទ្ធសភា នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។

### ៤.២ មុខងារតាមដានការអនុវត្តច្បាប់

-បានអញ្ជើញចុះបេសកកម្មសិក្សាឈ្វេងយល់ ស្តីពីការពង្រឹងកិច្ចការរដ្ឋបាលឃុំ

សង្កាត់ ក្រោយការបោះឆ្នោតសំដៅអភិវឌ្ឍន៍មូលដ្ឋាន ធានាបានសុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ នៅខេត្តព្រៃវែង ។

-បានអញ្ជើញចុះជួបសំណេះសំណាល ជាមួយក្រុមប្រឹក្សាឃុំព្រះប្រឡាយ ឃុំទំនប់ដាច់ ឃុំបាក់អន្លូង និងនគរបាលប៉ុស្តិ៍រដ្ឋបាលស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ដើម្បីឈ្វេងយល់ អំពីការងារបំរើសេវាជូនប្រជាពលរដ្ឋ ការធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ការងារអត្រានុកូលដ្ឋាន និងការងារភូមិ ឃុំ មានសុវត្ថិភាព។

### ៤.៣ មុខងារតំណាង

-បានទទួលពាក្យបណ្តឹងចំនួន៦ករណី បញ្ជូនពាក្យបណ្តឹងទៅក្រសួង រាជធានី ខេត្ត និងស្ថាប័នពាក់ព័ន្ធចំនួន១០ករណី ទទួលលិខិតឆ្លើយតបពីការដោះស្រាយពីស្ថាប័នពាក់ព័ន្ធបានចំនួន១ករណី កំពុងពិនិត្យសិក្សាចំនួន៥ករណី ធ្វើកំណត់បង្ហាញពាក្យបណ្តឹងបានចំនួន១០ករណី ឆ្លើយតបទៅម្ចាស់បណ្តឹងចំនួន១០ករណី តម្កល់ទុកមិនចាត់ការចំនួន១ករណី ទទួលឯកសារជូនជ្រាបពីក្រសួង-ស្ថាប័នពាក់ព័ន្ធចម្លងជូនគណៈកម្មការចំនួន៦ករណី ។

-បានអញ្ជើញចូលរួមក្នុងវេទិកាសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ ស្មៀននាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ ដឹកនាំដោយឯកឧត្តម ប៉ុល លឹម អនុប្រធានគណៈកម្មការទី៤ និងជាប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ នៅសាលប្រជុំសាលាខេត្តប៉ៃលិន

-បានអញ្ជើញចូលរួមសិក្ខាសាលាថ្នាក់តំបន់ ស្តីពីតួនាទីសភាក្នុងការលើកកម្ពស់ការឆ្លើយតបប្រកបដោយបរិយាប័ន្ន និងចីរភាព ចំពោះគ្រាអាសន្នសុខាភិបាល ករណីសិក្សាពីប្រសិទ្ធភាព និងឧបសគ្គ នៃការឆ្លើយតបថ្នាក់ជាតិចំពោះជំងឺកូវីដ-១៩ នៅសណ្ឋាគារRoyal Angkor Resort and Spa ខេត្តសៀមរាប ។

-បានអញ្ជើញចូលរួមប្រជុំជាមួយក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ ដើម្បីពិភាក្សាអំពីគម្រោងជួបសវនាការជាមួយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង និងការជួញដូរមនុស្ស, ជួបសវនាការជាមួយក្រសួងកិច្ចការនារី, ជួបសវនាការជាមួយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងត្រៀមរបាយការណ៍សកម្មភាព និងលទ្ធផលការងារប្រចាំអាណត្តិទី៤

-បានអញ្ជើញជាអធិបតី និងធ្វើបទបង្ហាញ ស្តីពីតួនាទី និងភារកិច្ចរបស់ព្រឹទ្ធសភា

ជូនដល់និស្សិតផ្នែកនីតិសាធារណៈមកពីសាខាសាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច ខេត្តក្រចេះ នៅសាលសិក្ខាសាលាបណ្ណាល័យព្រឹទ្ធសភា។

-បានអញ្ជើញដឹកនាំក្រុមអ្នកបច្ចេកទេស បុគ្គលិក កម្មករផ្នែកកសិកម្ម ដឹកកូនឈើផ្ចង់ និងកូនឈើបេងចំនួន៣.២២០ដើម យកទៅដាំនៅក្នុងតំបន់សួនសត្វភ្នំតាម៉ៅ។

-បានអញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តរបស់ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ ព្រឹទ្ធសភា សហការជាមួយសមាគមក្រុមគ្រូពេទ្យស្ម័គ្រចិត្តពីប្រទេសបារាំង អញ្ជើញចុះពិនិត្យជំងឺទូទៅជូនប្រជាពលរដ្ឋ ដោយឥតគិតថ្លៃ ស្ថិតនៅវត្តបន្ទាយមៀន ឃុំមៀន ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ។

-បានអញ្ជើញជាគណៈអធិបតី ក្នុងពិធីផ្សព្វផ្សាយខ្លឹមសារសំខាន់ៗ និងបទពិសោធន៍នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៥ ឆ្នាំ២០២២ ជូនដល់ក្រុមប្រឹក្សាស្រុក-ឃុំ ថ្នាក់ភូមិ នាយប៉ុស្តិ៍នគរបាលរដ្ឋបាល នាយកវិទ្យាល័យ និងនាយកអនុវិទ្យាល័យ សាលាបឋមសិក្សា សរុបចំនួន១៨២នាក់ ស្ថិតនៅសាលាស្រុកជលគីរី ខេត្តកំពង់ឆ្នាំង។

-បានអញ្ជើញចូលរួមពិធីផ្សព្វផ្សាយខ្លឹមសារសំខាន់ៗ នៃកម្មវិធីនយោបាយអភិវឌ្ឍឃុំ ជូនដល់ក្រុមប្រឹក្សាឃុំ យុវជន និងប្រជាពលរដ្ឋ សរុបចំនួន ១២០នាក់ ស្ថិតនៅសាលាស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។

-បានអញ្ជើញនាំយកអំណោយដ៏ថ្លៃថ្លារបស់សម្តេចប្រធានព្រឹទ្ធសភា និងលោកជំទាវ មានដូចជា: ម៉ាស៊ីនពិនិត្យសម្ពាធបេះដូង ចំនួន០១គ្រឿង ម្សៅទឹកដោះគោសម្រាប់ទារក និងកុមារ ម៉ាក PURELAC ចំនួន៥៤៧២កំប៉ុង. ជូនដល់មន្ទីរពេទ្យជ័យវរ្ម័នទី៧ តាមរយៈ លោកសាស្ត្រាចារ្យមហាបរិញ្ញាវេជ្ជបណ្ឌិត យ៉ៃ ចន្ទនា ប្រធានមន្ទីរពេទ្យជ័យវរ្ម័នទី៧ ស្ថិតនៅក្រុងសៀមរាប ខេត្តសៀមរាប។

-បានអញ្ជើញនាំយកទៀនព្រះវស្សា ទេយ្យទាន គ្រឿងឧបភោគ បរិភោគ និងបច្ច័យមួយចំនួនទៅវេរប្រគេនព្រះសង្ឃគង់ចាំព្រះវស្សានៅទីវត្តអារាម នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា។

-បានអញ្ជើញជាគណៈអធិបតី និងចូលរួមជាកិត្តិយសក្នុងពិធីផ្លូវការផ្សេងៗចំនួន ៣៨លើក។

-ដោយឡែក សមាជិក សមាជិកាព្រឹទ្ធសភាបានអញ្ជើញចុះជួបសំណេះសំណាល

សាកសួរសុខទុក្ខប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ ក្រុមគ្រូពេទ្យ អតីតមន្ត្រីរាជការជានិវត្តជន អតីតយុទ្ធជន ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាល និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីពង្រឹងតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំអាណត្តិទី៥ នៅមូលដ្ឋាន ឈ្វេងយល់អំពីវឌ្ឍនភាពការងារ ការងារសន្តិសុខសណ្តាប់ធ្នាប់ ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ពិនិត្យហេដ្ឋារចនាសម្ព័ន្ធ សម្ភោធសមិទ្ធផលនានា ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា នៅមូលដ្ឋានរាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តតាកែវ ខេត្តកែប ខេត្តកំពត ខេត្តកំពង់ស្ពឺ ខេត្តត្បូងឃ្មុំ ខេត្តស្វាយរៀង ខេត្តកោះកុង ខេត្តសៀមរាប ខេត្តកំពង់ធំ ខេត្តបាត់ដំបង ខេត្តឧត្តរមានជ័យ ខេត្តរតនគិរី ខេត្តបន្ទាយមានជ័យ និងខេត្តប៉ៃលិន ចំនួន១១៨លើក។

## ៤.៤ កិច្ចសហប្រតិបត្តិការអន្តរជាតិ

ការងារសហប្រតិបត្តិការអន្តរជាតិរបស់ព្រឹទ្ធសភា ជាពិសេស ទំនាក់ទំនងក្នុងកម្រិតតំបន់ និងអន្តរជាតិ សមាជិក សមាជិកាព្រឹទ្ធសភា បានចូលរួមយ៉ាងសកម្ម និងទទួលបានលទ្ធផលជាវិជ្ជមានដូចខាងក្រោម៖

-បានអញ្ជើញចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយលោក KIM JUNG NAM ប្រធានមូលនិធិចែករំលែកសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋកូរ៉េ ស្តីពីការផ្តល់ជំនួយមនុស្សធម៌ដល់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ ព្រឹទ្ធសភា នៅវិមានព្រឹទ្ធសភា។

-បានអញ្ជើញអមដំណើរគណៈប្រតិភូសភាកម្ពុជា ដឹកនាំដោយ ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ជាម យៀប** អនុប្រធានទី១ រដ្ឋសភា និងជាប្រធានគណៈកម្មការរៀបចំមហាសន្និបាតអន្តរសភាអាស៊ាន (AIPA) លើកទី៤៣ បំពេញទស្សនកិច្ចផ្លូវការនៅសាធារណរដ្ឋឥណ្ឌា ក្នុងឱកាសខួប៧០ឆ្នាំ នៃមិត្តភាពកម្ពុជា-ឥណ្ឌា និងខួប៣០ឆ្នាំ នៃមិត្តភាពអាស៊ាន-ឥណ្ឌា។

-បានអញ្ជើញចូលរួមប្រជុំគណៈកម្មាធិការនយោបាយ សម្រាប់មហាសន្និបាតអន្តរសភាអាស៊ាន (AIPA) លើកទី៤៣ នៅរដ្ឋសភា។

-បានអញ្ជើញចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ នៃគណៈកម្មាធិការស្ត្រីវ៉ាយប៉ា (WAIPA) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់លោកជំទាវកិត្តិសង្គហបណ្ឌិត **ឃួន សុដារី** ប្រធាន

គណៈកម្មាធិការស្ត្រីវ៉ាយប៉ា និងជាអនុប្រធានទី២ រដ្ឋសភា។

-បានអញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សាការងាររវាងគណៈប្រតិភូគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន នៃរដ្ឋសភា ដឹកនាំដោយឯកឧត្តម **សួស យ៉ារ៉ា** ប្រធានគណៈកម្មការ និងជាអនុប្រធានក្រុមមិត្តភាពរដ្ឋសភាកម្ពុជា-អាមេរិក ជាមួយនឹងគណៈប្រតិភូព្រឹទ្ធសភាសហរដ្ឋអាមេរិក ដឹកនាំដោយឯកឧត្តម Edward J. Markey សមាជិកព្រឹទ្ធសភា នៅរដ្ឋសភា។

-បានអញ្ជើញអមដំណើរគណៈប្រតិភូសហព័ន្ធនារីវៀតណាម ដឹកនាំដោយលោកជំទាវ **ហា ធីង៉ា** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សកុម្មុយនីស្ត និងជាសមាជិការដ្ឋសភា ប្រធានសហព័ន្ធនារីវៀតណាម ទស្សនកិច្ចខេត្តព្រះសីហនុ កំពត និងខេត្តកែប។

-បានអញ្ជើញជួបពិភាក្សាការងារជាមួយលោក Bernadette Bolo-Duthy តំណាងអង្គការលំនៅដ្ឋានមនុស្សជាតិប្រចាំនៅកម្ពុជា (Habital for Humanity Cambodia) ដើម្បីពិភាក្សាអំពីវឌ្ឍនភាពនៃសូចនាករសំខាន់ៗ ក្នុងការអនុវត្តគោលដៅអភិវឌ្ឍន៍ ដោយចីរភាព (SDG) ដើម្បីស្តាប់របាយការណ៍សង្ខេប ស្តីពីលទ្ធផលការងារក្នុងភាពជាដៃគូដែលអង្គការបានអនុវត្តដោយផ្ទាល់ជាមួយក្រសួងផែនការ ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ក្រសួងអភិវឌ្ឍន៍ជនបទ និងជាមួយអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ បានជួយបង្កលក្ខណៈឱ្យការអនុវត្តគោលនយោបាយកាត់បន្ថយភាពក្រីក្រ របស់រាជរដ្ឋាភិបាល ទទួលបានភាពជោគជ័យតាមការរំពឹងទុក រួមមាន៖ ការសាងសង់លំនៅដ្ឋានមានតម្លៃសមរម្យ ជូនបងប្អូនប្រជាពលរដ្ឋ នៅរាជធានីភ្នំពេញ ខេត្តបាត់ដំបង ខេត្តសៀមរាប ខេត្តត្បូងឃ្មុំ នៅសាលប្រជុំគណៈកម្មការទី៧។

ថ្ងៃសុក្រ ៧រោច ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២២

**ជ.ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

**កិត្តិសង្គហបណ្ឌិត ទេព ងន**

<u>ចម្លងជូន</u>

- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
- (ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសារ